មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

**វិចារណកថាព័ត៌មានរបស់ ម.ស.ម.ក**

ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១២

# រដ្ឋាភិបាលកម្ពុជាមានបំណងបិទហាងអ៊ីនធើណែតនៅភ្នំពេញ ជាលទ្ធផលបង្កនូវគ្រោះថ្នាក់មកលើសេរីភាពប្រើប្រាស់អ៊ីនធើណែត

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) សូមបង្ហាញនូវការព្រួយបារម្ភយ៉ាងខ្លាំងចំពោះសកម្មភាពថ្មីមួយ របស់រាជរដ្ឋាភិបាលកម្ពុជា (រដ្ឋាភិបាល) ដើម្បីរឹតត្បិតមកលើសេរីភាពប្រើប្រាស់អ៊ីនធើណែតនៅកម្ពុជា។ សកម្មភាពមួយនេះត្រូវបានរាយការណ៍នៅក្នុងសារព័ត៌មាន ឌឹ ខែមបូឌា ដេលី កាលពីថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១២ ចំណងជើង "សេចក្តីបង្គាប់របស់រដ្ឋាភិបាលប្រហែលជានាំឲ្យមានការបិទហាងអ៊ីនធើណែតជាច្រើននៅក្នុងក្រុង" ។

សារាចរណែនាំរបស់ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១០១២ អំពាវនាវឲ្យមានការរុះរើហាងអ៊ីនធើណែតទាំងអស់ដែលមានទីតាំងក្នុងចម្ងាយ ៥០០ម៉ែត្រ ជុំវិញសាលារៀន និងវិទ្យាស្ថានអប់រំនៅទីក្រុងភ្នំពេញ។ សារាចរគឺជាវិធានការណ៍ដែលចុះហត្ថលេខាដោយរដ្ឋមន្ត្រី ឬនាយករដ្ឋមន្ត្រី និងត្រូវបានប្រើប្រាស់ដើម្បីពន្យល់ពីច្បាប់ ឬផ្តល់នូវការណែនាំដោយយោងទៅលើច្បាប់។ សារាចរនេះមានលក្ខណៈជាការផ្តល់យោបល់ ហើយមិនមាននូវការចាប់បង្ខំតាមផ្លូវច្បាប់នោះទេ។ ស្រដៀងគ្នានឹងសេចក្តីប្រកាស វិសាលភាពនៃសារាចរមានកម្រិតប៉ុន្តែអាចប្រើប្រាស់បានភ្លាមៗ។ ប្រសិនបើអនុវត្តតាមសារាចរនេះ នឹងបង្កទៅជាការហាមឃាត់ស្ទើរតែទាំងស្រុងទៅលើហាងអ៊ីនធើណែតនៅក្នុងទីក្រុង ហេតុដូច្នេះ នេះគឺជាការរឹតបន្តឹងដោយគ្មានហេតុផលមកលើលទ្ធភាពប្រើប្រាស់អ៊ីនធើណែត សម្រាប់អ្នកមិនមានលទ្ធភាពមានកុំព្យូទ័រផ្ទាល់ខ្លួន។ មិនតែប៉ុណ្ណោះ សារាចរនេះថែមទាំងប្រកាសថា "ហ្គេមលើអ៊ីនធើណែតទាំងអស់" គឺខុសច្បាប់ ដូច្នេះបានចាត់ទុកហ្គេមទាំងនោះក្នុងកម្រិតរួមគ្នានឹង ភេរវកម្ម បទឧក្រិដ្ឋផ្នែកសេដ្ឋកិច្ច និងការមើលរូបអាសអាភាស។ ទោសសម្រាប់ការរំលោភបំពានលើសារាចរគឺរួមបញ្ចូលទាំងការបិទនូវហាងអ៊ីនធើណែត រឹបអូសសម្ភារៈ និងការចាប់ខ្លួន។

សារាចរនេះ មានលក្ខណៈស្រដៀងនឹងច្បាប់គ្រប់គ្រងអ៊ីនធើណែតដ៏ធ្ងន់ធ្ងរដែលត្រូវបានដាក់ឲ្យប្រើប្រាស់នៅក្នុងប្រទេសចិន និងប្រទេសវៀតណាម និងហាក់ដូចជាការឈានរបស់រដ្ឋាភិបាលមួយជំហានទៀត ដើម្បីបង្កើតនូវច្បាប់ប្រឆាំងនឹងឧក្រិដ្ឋកម្មលើអ៊ីនធើណែត។ សកម្មភាពមួយនេះមិនត្រឹមតែរឹតត្បិតមកលើសេរីភាពបញ្ចេញមតិ និងសេរីភាពទទួលព័ត៌មាននៅកម្ពុជា ដែលសេរីភាពទាំងពីរត្រូវបានធានាក្នុងច្បាប់រដ្ឋធម្មនុញ្ញនៃប្រទេសកម្ពុជា មាត្រា៤១ ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំង រំលោភបំពាននូវសេចក្តីប្រកាសរបស់ អង្គការសហ ប្រជាជាតិ លេខ L13 ស្តីពីការលើកកម្ពស់ ការការពារ និងការរីករាយក្នុងការអនុវត្តន៍សិទ្ធិមនុស្សនៅលើប្រព័ន្ធអ៊ីនធើណែតផងដែរ។

ឆ្លើយតបទៅនឹងការបង្ក្រាបលើហាងអ៊ីនធើណែតនេះ សន រ៉ាមណា មន្ត្រីសម្របសម្រួលគម្រោងសេរីភាពបញ្ចេញមតិ បានមានប្រសាសន៍ថា ៖

*"អ៊ីនធើណែតគឺមានសារៈសំខាន់ខ្លាំងណាស់សម្រាប់បុគ្គល ដែលមានបំណងចង់បញ្ចេញមតិ ឬក៏ចង់បញ្ចេញសំឡេងរបស់ខ្លួន។ អត្រាអ្នកប្រើប្រាស់អ៊ីនធើណែតនៅកម្ពុជា មានចំនួនតិចណាស់ទៅហើយ ប្រសិនបើប្រៀបធៀបជាមួយប្រទេសជិតខាង ដោយសារតែគម្លាតនៃលទ្ធភាពដែលអាចប្រើប្រាស់អ៊ីនធើណែតនៅក្នុងប្រទេសនេះ។ ប៉ុន្តែ អ៊ីនធើណែតមានប្រជាប្រិយភាពក្នុងចំណោមយុវជន ដែលបានប្រើប្រាស់អ៊ីនធើណែតដើម្បីបង្ហាញគំនិតរបស់ពួកគេ និងចែកចាយព័ត៌មាន។ កាលពីអតីតកាល ខ្ញុំគិតថា ប្រជាពលរដ្ឋកម្ពុជាមានសំណាង ដែលសិទ្ធិនៅលើអ៊ីនធើណែតនៅមិនទាន់រងការគាបសង្កត់ពីរដ្ឋាភិបាល មិនដូចជា ប្រទេសចិន វៀតណាម ឬប្រទេសថៃ។ ជាអកុសល ស្ថានភាពនេះបានផ្លាស់ប្តូរហើយ។ ជំនួសឲ្យការរឹតត្បិត រដ្ឋាភិបាលគួរតែទាញយកប្រយោជន៍ពីការកើនឡើងនៃបច្ចេកវិទ្យាដើម្បីធ្វើការទំនាក់ទំនងជាមួយប្រជាពលរដ្ឋ ដោយអនុញ្ញាតឲ្យមានការសន្ទនា ឬពិភាក្សា ជាជាងបំបិទគំនិត និងមតិប្រឆាំង"* ។

**សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនង ៖ កញ្ញា សន រ៉ាមណា តាមរយៈទូរសព្ទលេខ ០១៧ ៦៥៥ ៥៩១ ឬអ៊ីម៉ែល ៖ ramansorn@cchrcambodia.org ឬ កញ្ញា អូឡា ខេលី តាមរយៈទូរសព្ទលេខ ០៦៧ ៧២៧ ០២៥។**

<u>បណ្ណាធិការ</u>

ម.ស.ម.ក ត្រូវបានបង្កើតឡើងនៅក្នុង ខែវិច្ឆិកា ឆ្នាំ២០០២ ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេស សិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ នៅកម្ពុជា។

ម.ស.ម.ក គឺជាសមាជិករបស់ ដៃគូសន្ធនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (អ៊ីហ្វិក) ដែលជាបណ្តាញសកលដើម្បីការបញ្ចេញមតិដោយសេរី។

គេហទំព័រស្តីពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ទទួលបានរង្វាន់ប្រចាំឆ្នាំ២០១១របស់មូលនិធិនៃការបង្កើតថ្មីសម្រាប់សង្គមព័ត៌មានវិទ្យា ក្នុងចំណាត់ថ្នាក់នៃ សិទ្ធិ និងសេរីភាព